គម្ពីរអេភេសូរ

សំបុត្ររបស់ប៉ុល
ជល់ពួក

អេភេសូរ

សេចក្តីផ្តើម

នៅឆ្នាំហុកសិបពីរនៃគ្រីស្តសករាជ មានបុរសបួននាក់ចាកចេញពីទីក្រុងរ៉ូម ដើម្បីយកសំបុត្រទៅចែកជូនពួកជំនុំដែលស្ថិតនៅខេត្តមួយក្នុងឧបទ្វីបអាស៊ី ដែលសព្វថ្ងៃនេះយើងហៅថា ប្រទេសទួគី។ បុរសទាំងបួននាក់នោះ ចាកចេញពីមន្ទីរពន្ធនាគារ ពាំនាំគោលទ្ធិជំនឿដ៏សំខាន់សម្រាប់គ្រីស្តបរិស័ទ។ គោលទ្ធិនៃជំនឿទាំងនោះមានចងចាំនៅក្នុងចិត្តផង មាននៅក្នុងឯកសារសរសេរជាលាយលក្ខណ៍អក្សរផង។ ឯកសារដែលសរសេរជាលាយលក្ខណ៍អក្សរ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជំនឿរបស់គ្រីស្តបរិស័ទ។ សម័យនោះ រាជការ៉ូមមិនបានយល់ពីឥទ្ធិពលនៃខ្លឹមសារដែលសរសេរនៅក្នុងសំបុត្រទាំងនោះទេ។ បើប្រសិនណាជាគេដឹងវិញ ម្ល៉េះសមជាគេជម្រិតយក

សំបុត្រទាំងនោះមិនអោយធ្លាក់ទៅដល់ជន ដែលត្រូវទទួលសំបុត្រទាំងនោះទេ។

សាវ៉ែកប៉ុល បង្គាប់អោយបុរសទាំងបួននាក់នោះ យកសំបុត្រទៅចែកជូនពួកជំនុំនីមួយៗដែលរស់នៅតាមតំបន់នោះ។ តំបន់ទាំងនោះ ភាគច្រើនជាស្រុកកំណើតរបស់បុរសទាំងបួនរូប។ សំបុត្រទាំងបួនច្បាប់ មិនមែនគ្រាន់តែជាឯកសារសរសេរផ្តាល់ដៃតែប៉ុណ្ណោះទេ គឺជាព្រះបន្ទូលតែម្តង។ គ្រីស្ទបរិស័ទអោយឈ្មោះសំបុត្រទាំងនោះថា ជាសំបុត្ររបស់សាវ៉ែកប៉ុល ដែលសរសេរចេញពីមន្ទីរឃុំឃាំង។ យើងអោយឈ្មោះយ៉ាងដូច្នេះ ពីព្រោះក្នុងពេលដែលសាវ៉ែកប៉ុលសរសេរសំបុត្រទាំងបួននេះ លោកត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំងនាទីក្រុងរ៉ូម។ នៅក្នុងគម្ពីរកិច្ចការ លោកបានស្នើសូមសើរើរឿងក្តីរបស់លោកដល់ព្រះចៅសេសា។ មុននឹងព្រះចៅសេសាបើកសវនាការជំនុំជំរះរឿងក្តីរបស់សាវ៉ែកប៉ុល អាជ្ញាធរឃុំទុកសាវ៉ែកប៉ុលនៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នសិន។ ឯព្រះចៅសេសាដែលត្រូវជំនុំជំរះរឿងរបស់សាវ៉ែកប៉ុល ជាស្តេចមួយអង្គគ្រងរាជ្យនៅទីក្រុងរ៉ូម នាមស្តេចនេរ៉ូ។

បុរសទាំងបួននាក់នោះ ត្រូវយកសំបុត្រដើម្បីបញ្ជូនទៅដល់ក្រុមជំនុំនីមួយៗដូចមានជម្រាបខាងក្រោមនេះ។ មួយ លោកអេប៉ាប្រូឌីត មានស្រុកកំណើតនៅទីក្រុងភីលីព ត្រូវយកសំបុត្រពីសាវ៉ែកប៉ុល ទៅជូនក្រុមជំនុំនៅទីក្រុងភីលីព (សូមអានគម្ពីរគម្ពីរភីលីព៤:១៨)។ ទីពីរ លោកទីឃីកុស មានស្រុកកំណើតនៅទីក្រុងអេភេសូរ។ លោកទទួលសំបុត្រពីសាវ៉ែកប៉ុល យកទៅចែកជូនដល់ពួកជំនុំនៅទីក្រុងអេភេសូរនេះតែម្តង (សូមអានគម្ពីរអេភេសូរ៦:២១)។ ទីបី លោកអេប៉ាប្រាស មានស្រុកកំណើតនៅ

ស្រុកកូល៉ុស លោកជាអ្នកដែលកាន់សំបុត្រយកទៅអោយបានដល់ដៃពួកជំនុំនៅទីក្រុងកូល៉ុស (សូមអានគម្ពីរកូល៉ុស៤:១២)។ ទីបួន លោកអូនេស៊ីម ដែលត្រូវជាជើងឈ្នួលរបស់លោកភីលេម៉ូន។ លោកអូនេស៊ីមជាអ្នកស្រុកកូល៉ុសដែរ។ លោកកាន់សំបុត្រមួយច្បាប់ ដែលសាវ័កប៉ុលផ្ញើទៅកាន់លោកភីលេម៉ូនផ្ទាល់ ដែលជាអ្នកជឿព្រះអង្គមួយរូបទៀត។ លោកភីលេម៉ូនត្រូវជាចៅហ្វាយនាយរបស់លោកអូនេស៊ីម (សូមអានគម្ពីរភីលេម៉ូន១១)។

សំបុត្រទាំងបួនច្បាប់នេះ ជាការផ្គុំរូបភាពនៃអង្គព្រះយេស៊ូវគ្រីស្ទ រូបភាពក្រុមជំនុំរបស់ព្រះអង្គ រូបភាពជីវិតគ្រីស្ទបរិស័ទ រូបភាពទំនាក់ទំនង ព្រមទាំងរូបភាពមុខងារក្រុមជំនុំ ដែលរាប់បញ្ចូលទាំងពួកអ្នកជឿផង។ សំបុត្រទាំងបួនច្បាប់បរិយាយពីជីវិតគ្រីស្ទបរិស័ទ ដែលត្រូវរស់នៅក្នុងសីលធម៌ដ៏ខ្ពង់ខ្ពស់ជាទីបំផុត។ ឯសំបុត្រទាំងបួននោះ មានខ្លឹមសារដោយឡែកពីគ្នា ដូចជម្រាបជូនខាងក្រោម។

សំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ បរិយាយពីរូបកាយរបស់អង្គព្រះយេស៊ូវគ្រីស្ទ ពោលគឺជាក្រុមជំនុំសកល ដែលមានព្រះគ្រីស្ទទ្រង់ជាសិរសា។ សំបុត្រដែលសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំនៅទីក្រុងកូល៉ុស ជារូបភាពនៃអង្គព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជាសិរសារបស់ក្រុមជំនុំ។ សំបុត្រនោះសង្កត់ទៅលើតួអង្គព្រះយេស៊ូវគ្រីស្ទ ជាជាងទៅលើសារៈសំខាន់នៃក្រុមជំនុំ។ ឯសំបុត្រដែលសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ លោកសង្កត់ធ្ងន់ទៅលើខ្លឹមសារនៃរូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាពួកជំនុំ។ សំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងកូល៉ុស សង្កត់ធ្ងន់

ទៅលើអង្គព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ជាសិរសា។ រីឯសំបុត្រដែលសាវ័កសរសេរទៅកាន់ទីក្រុងភីលីពវិញ លោកសង្កត់ធ្ងន់ទៅលើការរស់នៅបរិសុទ្ធប្រចាំថ្ងៃនៃជីវិតគ្រីស្ទបរិស័ទ។ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទគ្រប់រូប ត្រូវរស់នៅដោយចេស្តានៃព្រះគ្រីស្ទ ដែលសណ្ឋិតនៅក្នុងចិត្តខ្លួន។ ឯខគម្ពីរនៃសំបុត្រដែលសាវ័កសរសេរទៅកាន់ពួកជំនុំទីក្រុងភីលីពបរិយាយថា "ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ"(ភីលីព៤:១៣)។ សំបុត្រដែលលោកសរសេរទៅកាន់លោកភីលេម៉ូន សាវ័កប៉ុលបញ្ជាក់ពីខ្លឹមសារនៃជំនឿលើគ្រីស្ទបរិស័ទ ក្នុងការរស់នៅប្រចាំថ្ងៃពិសេសជីវិតរស់នៅក្នុងសង្គមដែលមិនស្គាល់ព្រះជាម្ចាស់។ សាវ័កប៉ុលសរសេរសំបុត្រទៅកាន់លោកភីលេម៉ូន ដើម្បីអោយលោកទទួលលោកអូនេស៊ីម ដែលបានជឿដល់ព្រះអង្គនៅក្នុងមន្ទីរឃុំឃាំង។ សាវ័កប៉ុលចង់អោយលោកភីលេម៉ូនទទួលលោកអូនេស៊ីមវិញផង។ នៅក្នុងសំបុត្រនោះ លោកចែងយ៉ាងច្បាស់ថា "ដូច្នេះ បើអ្នករាប់ខ្ញុំទុកជាគូកន នោះចូរទទួលគាត់ទុកដូចជាខ្លួនខ្ញុំចុះ បើគាត់បានធ្វើអ្វីខុសឆ្គងនឹងអ្នក ឬជំពាក់អ្នក នោះត្រូវគិតលើខ្ញុំវិញ" (ភីលេម៉ូន១៧-១៨)។

ប្រហែលជាសតវត្សរ៍ទីមួយ ដំណឹងល្អទាំងបួនរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទរស់រានមានជីវិត ព្រមទាំងបង្កើតផលផ្លែយ៉ាងផុសផុលនៅម្តុំមជ្ឈិមបូព៌ា។ ប្រមាណជាសាមសិបឆ្នាំក្រោយមកទៀត សាវ័កប៉ុលបានសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ។ ខ្លឹមសារដែលបង្កប់នៅក្នុងសំបុត្រនោះ លោកបញ្ជាក់ថាគ្រីស្ទបរិស័ទអាចរស់នៅក្នុងជីវិតបរិសុទ្ធថ្វាយព្រះជាម្ចាស់បាន។ ដើម្បីរស់នៅក្នុងជីវិតបរិសុទ្ធ

អ្នកជឿលើព្រះអម្ចាស់គ្រប់រូប ចាំបាច់ត្រូវរស់ដោយកម្លាំងរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ដោយឡែក ក្នុងមេរៀននេះ យើងសិក្សាពីខ្លឹមសារនៃសំបុត្រដែលសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ។

គម្ពីរអេភេសូរ សម្តែងពីទ្រង់ទ្រាយនៃក្រុមជំនុំថា ជាផ្ទាំងគំនូរដែលព្រះជាម្ចាស់ទ្រង់ចានគូរ។ មិនតែប៉ុណ្ណោះ គម្ពីរអេភេសូរបើកសម្តែងអោយយើងស្គាល់ថា ក្រុមជំនុំ ជាអាថ៌កំបាំងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ បើកសម្តែងអោយស្គាល់ក្នុងព្រះគម្ពីរសញ្ញាថ្មី គម្ពីរអេភេសូរ២:១០ចែងថា "ដ្បិតយើងរាល់គ្នាជាស្នាដៃដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឱ្យយើងរាល់គ្នាប្រព្រឹត្តតាម"។ ក្រុមជំនុំមានលក្ខណៈវិសេសជាងវិហារដែលសង់ពីថ្ម ដោយដៃមនុស្ស។ ក្រុមជំនុំរបស់ព្រះជាម្ចាស់មានព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គគង់នៅជាមួយ។ រូបកាយរបស់អង្គព្រះយេស៊ូវគ្រីស្ទ ដែលតាំងនៅក្នុងលោកនេះ ត្រូវជើរតាមលំអានជានដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានបន្សល់ទុកមក។ មិនតែប៉ុណ្ណោះ រូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្រូវរស់នៅលើលោកនេះ ដោយមានការប្រុងប្រយ័ត្នជានិច្ចចំពោះគំនិតទាស់ទទឹងនឹងផែនការព្រះ ព្រមទាំងអន្ទាក់របស់សាតាំងនិងពួកពលបរិវាររបស់វា ដែលទាក់ក្រុមជំនុំអោយធ្លាក់ចេញពីផ្លូវរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លើសពីនោះ គម្ពីរអេភេសូរបើកសម្តែងអោយយើងដឹងថា នៅថ្ងៃមួយ ព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមកលើកក្រុមជំនុំរបស់ព្រះអង្គទៅនៅជាមួយទ្រង់ រួចហើយសម្អាតពួកជំនុំទ្រង់អោយទៅជាភរិយាថ្មោងថ្មីរបស់ព្រះអង្គ។

គម្ពីរអេភេសូរមានខ្លឹមសារយ៉ាងជ្រាលជ្រៅទាំងគោលទ្ធិ ទាំងការអនុវត្តន៍។ ដោយសារមូលហេតុនេះ ខ្ញុំសូមសារភាពនៅចំពោះលោកអ្នកបងប្អូនថា ខ្ញុំមិនបានយល់ជម្រៅនិងកំពស់នៃគោលទ្ធិដ៏មានខ្លឹមសារបង្កប់នៅក្នុងព្រះគម្ពីរអេភេសូរទាំងស្រុងទេ។ ក្នុងការសិក្សាព្រះគម្ពីរអេភេសូរ យើងគ្រាន់តែខំប្រឹងប្រែងអោយយល់អស់ពីសមត្ថភាពតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ បណ្តាលអោយយើងយល់តាមកម្រិត យើងអាចយល់បានក្នុងនាមយើងជាមនុស្សជាតិ។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ មិនអនុញ្ញាតអោយសាវ័កប៉ុល ធ្វើដំណើរទៅទីក្រុងអេភេសូរក្នុងដំណើរបេសកកម្មលើកទីពីររបស់លោកទេ។ ក្នុងគម្ពីរកិច្ចការ១៦:៦យើងឃើញសេចក្តីនេះចែងថា "កាលបានដើរកាត់ស្រុកព្រីគា នឹងដែនខេត្តកាឡាទីនោះព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ឃាត់ មិនឱ្យផ្សាយព្រះបន្ទូលនៅស្រុកអាស៊ីទេ"។ យើងមិនដឹងពីមូលហេតុដែលព្រះវិញ្ញាណរបស់ព្រះអង្គរារាំងមិនអោយសាវ័កប៉ុលចុះទៅទីនោះ។ ប៉ុន្តែយើងដឹងច្បាស់ថា ពេលវេលារបស់ព្រះជាម្ចាស់ត្រឹមត្រូវ ហើយល្អគ្រប់បែបយ៉ាងទាំងអស់។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ បំបែរមុខសាវ័កប៉ុលអោយធ្វើដំណើរឆ្ពោះទៅទិសខាងលិច គឺទៅខេត្តម៉ាសេដូន ដែលមានទីក្រុងភីលីព ទីក្រុងបេរា ទីក្រុងអាថែន និងទីក្រុងកូរិនថូសជាដើម។ បន្ទាប់ពីនោះមក ទើបព្រះជាម្ចាស់អនុញ្ញាតអោយសាវ័កប៉ុល ត្រឡប់មកទីក្រុងអេភេសូរវិញ។ នៅពេលលោកធ្វើដំណើរមកដល់ទីក្រុងអេភេសូរ លោកឃើញទិដ្ឋភាពមួយ ដែលមានលក្ខណៈល្អប្រសើរក្រៃលែង។ គម្ពីរកិច្ចការ១៨:១៩ចែងថា "កាលទៅដល់ក្រុងអេភេសូរហើយ នោះប៉ុលទុកគេនៅទីនោះ តែគាត់ចូលទៅក្នុងសាលាប្រជុំរបស់

សាសន៍យូដា ហើយក៏ជជែកពន្យល់ដល់គេ"។

នៅពេលសាវ័កប៉ុលត្រឡប់មកដល់ទីក្រុងអេភេសូរ លោកមានការលើកទឹកចិត្តជាខ្លាំង។ នៅក្នុងដំណើរបេសកកម្មលើកទីបី លោកបានដឹងថា មានបុរសម្នាក់ឈ្មោះអ័ប៉ុឡុសបានធ្វើការផ្សាយដំណឹងល្អនៅទីនោះដែរ។ ការនោះកើតមានឡើងចន្លោះដំណើរបេសកកម្មរបស់សាវ័កប៉ុលលើកទីពីរ និងលើកទីបី។ លោកអ័ប៉ុឡុសអធិប្បាយពីការជ្រមុជទឹករបស់លោកយ៉ូហាន។ លោកមិនទាន់បានស្គាល់ពីដំណឹងល្អនៃព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ ក្រោយមកទៀត ទើបលោកបានដឹងពីដំណឹងល្អនៃព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ចាប់ពីពេលនោះមក លោកបានទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះរបស់លោក។ លោកក៏ចេះអធិប្បាយពីដំណឹងល្អនៃព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទយ៉ាងភ្លៀវឆ្លាជាទីបំផុត។

នៅទីក្រុងអេភេសូរ សាវ័កប៉ុលបានចំណាយពេលប្រមាណពីរឆ្នាំ ដើម្បីបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយប្រើប្រាស់ទីសាលាសាធារណៈមួយកន្លែងឈ្មោះទីរ៉ានុស។ ការអធិប្បាយព្រះបន្ទូលព្រះអង្គអស់រយៈពេលពីរឆ្នាំ ញុំាងអោយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជ្រាបចូលទៅគ្រប់ទីកន្លែងនៃឧបទ្វីបអាស៊ីចុងខាងលិច។ ជាលទ្ធផលក្រុមជំនុំដែលសម្តែងក្នុងគម្ពីរវិវរណៈជំពូក២-៣ គឺជាក្រុមជំនុំដែលកកើតឡើងដោយសារសាវ័កប៉ុលអធិប្បាយព្រះបន្ទូលនៅទីក្រុងអេភេសូរ។ បើតាមការសិក្សាស្រាវជ្រាវអោយបានហ្មត់ចត់ បូកបញ្ចូលនឹងការជីករកឃើញវត្ថុបុរាណនិងឥទ្ធិពលនៃគ្រីស្ទបរិស័ទនៅក្នុងពេលបច្ចុប្បន្ននេះ មនុស្សរាប់លាននាក់ដែលរស់នៅ

ទីក្រុងអេភេសូរ និងខេត្តជិតខាងបានទទួលជឿព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ទីក្រុងអេភេសូរជាបេះដូងនៃចក្រភពរ៉ូមទាំងមូល។ វប្បធម៌ ប្រពៃណីរបស់សាសន៍ក្រេកមិនសូវមានអ្នកស្រុកគោរពប៉ុន្មានទេនៅក្នុងប្រទេសក្រេក ប៉ុន្តែអ្នកស្រុកដែលរស់នៅក្នុងព្រំដែនខាងលិចប្រទេសទួគី ជាអ្នកអនុវត្តអារ្យធម៌ប្រពៃណីសាសន៍រ៉ូមខ្លាំងជាងគេ។ ទីក្រុងអេភេសូរតាំងនៅតំបន់នោះ។ ទីក្រុងអេភេសូរជាមជ្ឈមណ្ឌលវប្បធម៌ និងមជ្ឈមណ្ឌលសាសនាជ៍ខ្លាំងក្លាផងដែរ។ ធាតុអាកាសនៅតំបន់នោះ មិនត្រជាក់ពេក មិនក្តៅពេក។ ពួករាជការព្រះរាជាណាចក្ររ៉ូម ច្រើនធ្វើដំណើរមកសម្រាកកាយពេលវិស្សមកាលរបស់ខ្លួននៅទីក្រុងអេភេសូរ។

ទីក្រុងអេភេសូរជាក្រុងសំខាន់មួយនៅក្នុងឧបទ្វីបអាស៊ីចុងខាងលិច។ ទីក្រុងនេះ ជាទីក្រុងទីពីរ ដែលលូតលាស់យ៉ាងខ្លាំងបន្ទាប់ពីទីក្រុងរ៉ូម។ នៅឆ្នាំ២០០០ ម.គ.ស. ពួកសាសន៍ហេតបានសង់ទីក្រុងនេះឡើង។ រយៈពេល១០០០ឆ្នាំ ទីក្រុងអេភេសូររាប់ថា ជាទីក្រុងដែលមានរសជាតិ និងទ្រង់ទ្រាយជាជនជាតិអាស៊ីរស់នៅ។ លុះមកទល់ឆ្នាំ១០០០មុនគ្រីស្ទសករាជ សាសន៍ក្រេកជាជនជាតិនៅទ្វីបអឺរ៉ុប បានចូលមកគ្រប់គ្រងទីក្រុងអេភេសូរ។ ទីក្រុងអេភេសូរជាកន្លែងដែលប្រជាពលរដ្ឋនៅទ្វីបលោកខាងលិច និងទ្វីបលោកខាងកើតរស់នៅលាយឡំគ្នា។

មិនតែប៉ុណ្ណោះ ទីក្រុងអេភេសូរជាទីក្រុងពាណិជ្ជកម្មថែមទៀតផង។ ប្រមាណអស់រយៈពេល២៥០០ឆ្នាំ ទីក្រុងអេភេសូរជាកំពង់ផែសម្រាប់ដោះដូរទំនិញពីទ្វីបអឺរ៉ុប និងទ្វីបអាស៊ី។ កំពង់ផែនោះតាំងនៅប្រមាណជាដប់គីឡូម៉ែត្រ ឆ្ងាយពីឆ្នេរ

សមុទ្របច្ចុប្បន្ន។ នៅសម័យសាវ័កប៉ុលចូលទៅផ្សាយដំណឹងល្អនៅទីក្រុងអេភេសូរ លោកបានជិះសំពៅចូលទៅដល់កំពង់ផែនោះតែម្តង។ សព្វថ្ងៃកំពង់ផែនោះមិនមានទៀតទេ ដ្បិតដីល្បាប់បានលប់បាត់អស់ទៅហើយ។

លើសពីនោះទៅទៀត ទីក្រុងអេភេសូរជាមជ្ឈមណ្ឌលសាសនា និងសិល្បៈយ៉ាងល្បីល្បាញ។ នៅទីក្រុងអេភេសូរមានវិហារមួយឈ្មោះវិហារព្រះនាងទេពធីតាឌីអាន។ វិហារនេះចាត់ទុកថា ជាបីតិកភណ្ឌពិភពលោកទាំងប្រាំពីរដែលមាននៅលើលោកយើងនេះ។ វិហារនោះធំណាស់ មានទទឹង៧៣ម៉ែត្រ បណ្តោយ១២៧ម៉ែត្រ។ គ្រឹះនៃវិហារនោះធ្វើពីស្បែក ហើយនិងធ្យូងដើម្បីការពារមិនអោយមានការខូចខាតពេលកក្រើកដី។ ធនធានដែលយកមកសង់វិហារនោះ បានមកពីអ្នកស្រុកដែលរស់នៅក្នុងទីក្រុងអេភេសូរ។ វិហារនោះមានសសរ១២៧ ដែលឆ្លាក់ក្បូរក្បាច់រចនា ព្រមទាំងរំលេចពណ៌យ៉ាងស្រស់បំព្រង។ នៅក្នុងវិហារនោះ មានរូបសំណាកមួយឈ្មោះព្រះនាងទេពធីតាឌីអាន។ រូបភាពរបស់ព្រះនាងទេពធីតាឌីអាន មានលក្ខណៈខុសប្លែកពីព្រះឌីអាន ដែលគេនាំមកពីប្រទេសអ៊ីរ៉ុប។ ព្រះនាងទេពធីតាឌីអានមានលក្ខណៈជាព្រះនាងទេពធីតាសាយភ្នំនៃប្រជាពលរដ្ឋអាស៊ីវិញ។ ព្រះនាងទេពធីតាសាយភ្នំនាមឌីអានមានដោះច្រើនណាស់។ ដោយសារព្រះនាមទេពធីតាអាចបង្កើតកូនបានច្រើន នៅសម័យនោះ គេយកសុទ្ធតែស្រីក្រមុំមកបម្រើព្រះនាងទេពធីតាឌីអាន។ ស្រីក្រមុំទាំងនោះ ត្រូវបម្រើកាមគុណដល់បុរសដែលចូលមកថ្វាយបង្គំដល់ព្រះនាងទេពធីតាឌីអាន។ ដោយសារទីក្រុងអេភេសូរមានព្រះវិហារធំមួយឈ្មោះថា ព្រះវិហារសម្រាប់ព្រះនាង

ទេពធីតាឌីអាន ពួកទេសចរជាច្រើន បានធ្វើដំណើរទៅទស្សនាទីនោះ។ នៅពេលចាកចេញពីទីក្រុងអេភេសូរមកវិញ ពួកទេសចរទិញយករូបសំណាកព្រះវិហារឌីអានមកជាមួយ។ រូបសំណាកនៃព្រះវិហារឌីអាន ខ្លះធ្វើពីមាស ខ្លះធ្វើពីប្រាក់ ខ្លះធ្វើពីឈើ ខ្លះធ្វើពីលង្ហិន។ អ្នកធ្លាក់រូបព្រះវិហារនោះ រកកម្រៃបានយ៉ាងច្រើនដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន។ អ្នកខ្លះធ្វើជាអ្នកមាន ដោយសារកម្រៃពីការលក់ដូររូបសំណាកព្រះវិហារនោះផងដែរ។

ទិដ្ឋភាពនៃទីក្រុងអេភេសូរ មានឥទ្ធិពលដូចបានជម្រាបជូនខាងលើ គឺមានឥទ្ធិពលខាងវប្បធម៌ ប្រពៃណី ពាណិជ្ជកម្ម ព្រមទាំងឥទ្ធិពលខាងសាសនា និងសិល្បៈ។ សាវ័កប៉ុលចូលទៅផ្សាយដំណឹងល្អ ដល់មនុស្សដែលរស់នៅក្រោមបរិយាកាសបែបនោះ។ ពេលលោកចូលទៅដល់ក្រុងអេភេសូរជាលើកដំបូង លោកបានចូលទៅអធិប្បាយព្រះបន្ទូលព្រះអង្គនៅសាលាប្រជុំរបស់សាសន៍យូដា។ លោកនៅទីនោះអស់រយៈពេលបីខែ។ បន្ទាប់មកទៀត លោកបានជួលទីសាលាសាធារណៈមួយកន្លែងឈ្មោះទីរ៉ានុស ហើយបង្ហាត់បង្រៀនព្រះបន្ទូលនៅទីនោះអស់រយៈពេលពីរឆ្នាំ។ គម្ពីរកិច្ចការ ១៩:១០ចែងបញ្ជាក់ថា "គាត់ធ្វើដូច្នោះ អស់២ឆ្នាំ ដល់ម្ល៉េះបានជាអស់អ្នក ដែលនៅស្រុកអាស៊ីបានឮព្រះបន្ទូលនៃព្រះអម្ចាស់ ទាំងសាសន៍យូដា នឹងសាសន៍ក្រេកផង"។ សាវ័កប៉ុលទទួលផលជាច្រើន ពេលដែលលោកផ្សាយដំណឹងល្អនៅក្នុងទីក្រុងអេភេសូរ។ នៅទីនោះអ្នកស្រុកទទួលដំណឹងល្អដោយរីករាយ។ នៅក្នុងភូមិសាស្ត្រទាំងអម្បាលមាណដែលសាវ័កប៉ុលបានចុះទៅផ្សាយដំណឹងល្អ មិនមានអ្នកស្រុកនៅទីណា

បានទទួលដំណឹងល្អយ៉ាងរីករាយដូចអ្នកស្រុកអេភេសូរទេ។ ដោយសារមូលហេតុនេះ ហើយ បានជាគេអាចយល់ខ្លឹមសារនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចសាវ័កប៉ុល សរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរនេះ។

ទាក់ទងនឹងខ្លឹមសារនៃសំបុត្រដែលសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំនីមួយៗ លោកសរសេរមានលក្ខណៈដោយឡែកៗពីគ្នា។ ចំពោះពួកជំនុំនៅទីក្រុងកូរិនថូស លោកសរសេរថា "ប៉ុន្តែ ខ្ញុំនឹងនៅក្រុងអេភេសូរ ទាល់តែដល់បុណ្យថ្ងៃទី៥០ ដ្បិតមានទ្វារយ៉ាងធំ ហើយស្រួលបានបើកចំហឱ្យខ្ញុំ ហើយក៏មានពួកឃាត់ឃាំងជាច្រើនដែរ" (១កូរិនថូស១៦:៨-៩)។ លោកជម្រាបដល់ពួកជំនុំនៅទីក្រុងកូរិនថូសថា នៅទីក្រុងអេភេសូរ សេចក្តីអធិប្បាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើអោយជាងឆ្លាក់ប្រាក់អស់ការងារធ្វើ។ ពួកជាងទាំងនោះនាំគ្នាអុចអាលអ្នកស្រុក អោយងើបឡើងបះបោរពេញទាំងទីក្រុងអេភេសូរ។ នៅទីក្រុងអេភេសូរ សាវ័កប៉ុលអធិប្បាយពីព្រះអម្ចាស់យេស៊ូវគ្រីស្តថា ជាព្រះមានព្រះជន្មរស់។ ព្រះអង្គយាងចូលក្នុងចិត្តអស់អ្នកណាដែលជឿដល់ទ្រង់។ មានពេលខ្លះ សាវ័កប៉ុលទទួលការអស់ទឹកចិត្តដែរ ពេលលោកស្នាក់នៅទីក្រុងអេភេសូរ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះជាម្ចាស់ចេះតែជម្រុញចិត្តសាវ័កប៉ុលអោយខំផ្សព្វផ្សាយដំណឹងល្អទៅមុខទៀត បើតាមសេចក្តីដែលចែងក្នុងគម្ពីរកិច្ចការ១៩:២៣-៤១។ សាវ័កប៉ុលស្រឡាញ់ពួកជំនុំនៅទីក្រុងអេភេសូរខ្លាំងណាស់។ នៅក្នុងគម្ពីរកិច្ចការ២០:១៧-៣៨ លោកបានចែងអោយយើងដឹងថា លោកបានអធិស្ឋានលាពួកអ្នកចាស់ទុំពួកជំនុំនៅទីក្រុងអេភេសូរ ដោយមានសេចក្តីស្រឡាញ់យ៉ាងស្និទ្ធស្នាល។

នៅក្នុងទីក្រុងអេភេសូរមានអ្នកជឿដល់ព្រះជាម្ចាស់ច្រើនណាស់។ សាវ័កប៉ុលស្នាក់នៅទីនោះជាយូរថ្ងៃ ចានជាលោកអាចបង្ហាត់បង្រៀនសេចក្តីពិតខាងព្រលឹងវិញ្ញាណយ៉ាងជ្រាលជ្រៅ ដូចលោកសរសេរក្នុងសំបុត្រនេះ។ អ្នកស្រុកនៅទីនោះយល់សេចក្តីដែលសាវ័កប៉ុលសរសេរ។ បើអ្នកស្រុកនោះមិនយល់ពីសេចក្តីទាំងនេះទេ សាវ័កប៉ុលមិនសរសេរបែបនោះទេ។ នៅក្នុងគម្ពីរវិវរណៈយើងឃើញថា ពួកជំនុំទីក្រុងអេភេសូរ គឺជាពួកជំនុំមួយក្នុងចំណោមពួកជំនុំទាំងប្រាំពីរ។ ពួកជំនុំអេភេសូរមានការយល់ដឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងជ្រាលជ្រៅ ពិសេសផ្នែកខាងព្រលឹងវិញ្ញាណ។

បើយើងប្រៀបធៀបកម្រិតយល់ដឹងខាងព្រលឹងវិញ្ញាណ របស់ពួកជំនុំនៅទីក្រុងអេភេសូរ នឹងកម្រិតព្រលឹងវិញ្ញាណដែលយើងស្គាល់ព្រះជាម្ចាស់ក្នុងក្រុមជំនុំយើងសព្វថ្ងៃ យើងមិនអាចប្រៀបផ្ទឹមគ្នាបានទាល់តែសោះ។ ពួកជំនុំនៅទីក្រុងអេភេសូរស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រីស្តយ៉ាងប្តូរផ្តាច់។ មួយថ្ងៃៗគេដើរជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្តក្នុងជីវិតបរិសុទ្ធ។ ខ្ញុំចូលចិត្តធ្វើជាគ្រូគង្វាលរបស់ពួកជំនុំយើងសព្វថ្ងៃនេះដែរ។ ប៉ុន្តែ ខ្ញុំសូមសារភាពថា ក្រុមជំនុំយើងសព្វថ្ងៃ ដើរឆ្ងាយពីព្រះអម្ចាស់យេស៊ូវគ្រីស្តខ្លាំងណាស់។ ក្រុមជំនុំរបស់យើងផ្តោតខ្លាំងទៅលើកម្មវិធី ផ្តោតខ្លាំងទៅលើរដ្ឋបាល ព្រមទាំងផ្តោតខ្លាំងទៅលើវិធីធ្វើការងារ គឺមិនបានចំណាយពេលអោយបានច្រើនជាទីបំផុតដើរកៀកជិតនឹងព្រះអម្ចាស់យេស៊ូវទេ។ កិរិយាទាំងនេះត្រូវបង្ហាញអោយឃើញពីជម្រៅនៃសេចក្តីស្រឡាញ់របស់យើង ចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ត។

សាវ័កប៉ុលសរសេរសំបុត្រទៅកាន់ពួកជំនុំទីក្រុងអេភេសូរបញ្ជាក់ថា ព្រះគ្រីស្តស្រឡាញ់ដល់ពួកជំនុំ បានជាព្រះអង្គប្រគល់អង្គទ្រង់បង្កើតជាពួកជំនុំឡើង។ ក្នុងពេលដែលយើងកំពុងបម្រើព្រះអម្ចាស់យេស៊ូវគ្រីស្តសព្វថ្ងៃ យើងត្រូវសួរខ្លួនយើងថា តើយើងពិតជាស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រីស្តមែនឬមិនមែន? តើយើងឆ្លើយតបចំពោះព្រះអង្គដោយរបៀបណា? តើយើងអាចនិយាយអស់ពីដួងចិត្តរបស់យើងបានថា "ខ្ញុំស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រីស្ត ដ្បិតទ្រង់ស្រឡាញ់ខ្ញុំជាមុន"។ តើយើងអាចនិយាយពាក្យនេះបានដែរឬទេ? ការសិក្សាខ្លឹមសារនៃព្រះគម្ពីរអេភេសូរ គួរនាំយើងបែរត្រឡប់មកជើរយ៉ាងជិតស្និទ្ធជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្តជារៀងរាល់ថ្ងៃ។

នៅក្នុងគម្ពីរទាំងមូល មានគម្ពីរពីរដែលពិចារកយល់ជាងគេ។ គម្ពីរមួយ គឺគម្ពីរអេភេសូរ គម្ពីរមួយទៀត គឺជាគម្ពីរវិវរណៈ។ ដោយសារព្រះគម្ពីរទាំងពីរកណ្ឌនេះ មានការពិចារកយល់ខ្ជាំងពេក អ្នកប្រកាន់គោលទ្ធិបែបសើរនិយម គេមិនសូវរាប់អានគម្ពីរទាំងពីរនេះទេ។ អ្នកទាំងនោះយល់ថា គម្ពីរអេភេសូរមានសេចក្តីពិតខាងព្រលឹងវិញ្ញាណខ្ពស់ ហួសពីមនុស្សបច្ចុប្បន្ននេះអាចអនុវត្តបាន។ ចំណែកគម្ពីរវិវរណៈវិញ គេយល់ថា គ្រាន់តែជារឿងស្រមើស្រមៃរបស់មនុស្សមួយរូប។ ថ្វីដ្បិតកណ្ឌព្រះគម្ពីរទាំងពីរនេះមានការពិចារកយល់ កណ្ឌព្រះគម្ពីរនេះពិតជាមានខ្លឹមសារខាងព្រលឹងវិញ្ញាណសម្រាប់អោយយើងជាគ្រីស្តបរិស័ទសម័យបច្ចុប្បន្ន អាចយកមកអនុវត្តបាន។

បើសិក្សាអោយបានហ្មត់ចត់ យើងឃើញថា គម្ពីរអេភេសូរហើយនិងគម្ពីរវិវរណៈ បានសរសេរឡើងយ៉ាងមានរបៀបរៀបរយជាទីបំផុត តាមប្រព័ន្ធគណិតវិទ្យា

និងសត្ថវិទ្យា។ សេចក្តីពិតដែលមានសម្តែងនៅក្នុងគម្ពីរនេះពិបាកយល់ច្រាកដមែន។ នៅលើលោកនេះ គ្មានជនណាម្នាក់ដែលអាចបកស្រាយខគម្ពីរទាំងពីរនេះបានត្រឹមត្រូវល្អឥតខ្ចោះនោះទេ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ យើងឃើញថា កណ្ឌព្រះគម្ពីរទាំងពីរនេះមានលក្ខណៈរៀបរយ ងាយយកមកធ្វើជាគម្រោងសិក្សា បានជាងគម្ពីរណាៗទាំងអស់។ ខ្ញុំសូមសារភាពថា ខ្ញុំមិនបានយល់គម្ពីរអេភេសូរ និងគម្ពីរវិវរណៈអោយបានជ្រៅជ្រះជាងអ្នកដទៃទេ។ ខ្ញុំគ្រាន់តែនិយាយថា គម្ពីរទាំងពីរនេះអាចយកមករៀបរយធ្វើជាគម្រោងមេរៀនបានងាយជាងគម្ពីរដទៃៗទៀត។

សាវ័កប៉ុលសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ ជាលក្ខណៈងាយ មានវគ្គ មានស្មើយ៉ាងត្រឹមត្រូវ។ ចំណែកលោកយ៉ូហានដែលកត់ត្រាទុកសេចក្តីដែលចែងទុកក្នុងព្រះគម្ពីរវិវរណៈ ក៏លោកកត់ត្រាទុកមានវគ្គ មានស្មើយ៉ាងត្រឹមត្រូវដែរ។ នៅក្នុងព្រះគម្ពីរអេភេសូរទាំងអស់មានចំនួនប្រាំមួយជំពូក។ ជំពូក១-៣ បរិយាយពីការត្រាស់ហៅដល់ពួកជំនុំ ព្រមទាំងគោលទ្ធិនៃក្រុមជំនុំ។ ជំពូក៤-៦ បរិយាយពីកិរិយាប្រព្រឹត្តរបស់ពួកជំនុំ ជាការអនុវត្តន៍ប្រចាំថ្ងៃក្នុងជីវិតរបស់ខ្លួន។ ក្រុមជំនុំរបស់ព្រះជាម្ចាស់មានព្រះយេស៊ូវគ្រីស្តជាសិរសា។ អង្គព្រះគ្រីស្តគង់នៅឯស្ថានសួគ៌។ ពួកជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ត ត្រូវមានលក្ខណៈដូចអង្គព្រះយេស៊ូវ។ សិរសារបស់រូបកាយស្ថិតនៅស្ថានសួគ៌ រីឯជើងរបស់រូបកាយ គឺជាក្រុមជំនុំស្ថិតនៅលើផែនដីនេះ។ សាវ័កប៉ុលចង់បញ្ជាក់នៅក្នុងគម្ពីរអេភេសូរថា ធម្មតាយើងជាក្រុមជំនុំ ដែលជាព្រះបាទារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ត មិនមែនស្ថិតនៅលើស្ថានសួគ៌រហូតទេ។ លោកមាន

ប្រសាសន៍ថា "ដូច្នេះ ខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឱ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារ ដែលទ្រង់បានហៅមកធ្វើចុះ"(អេភេសូរ៤:១)។ នៅក្នុងខនេះ សាវ័កប៉ុលចង់មានប្រសាសន៍ថា គ្រីស្ទបរិស័ទមិនត្រូវអួតខ្លួនពីតួនាទី ដែលព្រះជាម្ចាស់ប្រទានអោយយើងមានឯកសិទ្ធិរស់នៅស្ថានសួគ៌តែម្យ៉ាងប៉ុណ្ណោះ។ បន្ទាប់ពីយើងបានជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះរបស់យើងហើយ យើងត្រូវចុះពីស្ថានសួគ៌មកដើរនៅលើផែនដី ដែលមានពោរពេញទៅដោយអំពើបាប។ សូមចាំថា នៅសម័យសាវ័កប៉ុលរស់នៅ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្រូវរស់នៅក្នុងសង្គម ដែលមនុស្សភាគច្រើនជាអ្នកមិនជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ។ មិនតែប៉ុណ្ណោះ សង្គមដែលគ្រីស្ទបរិស័ទត្រូវរស់នៅជាមួយនោះ គឺជាសង្គមដែលមើលងាយមើលថោកដល់ជំនឿ និងដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទថែមទៀតផង។ ជំពូក១-៣ បរិយាយពីគោលទ្ធិនៃជំនឿរបស់គ្រីស្ទបរិស័ទ។ ជំពូក៤-៦ បរិយាយពីជីវិតរស់នៅជាក់ស្តែងរបស់អ្នកជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទក្នុងពិភពលោក ដែលមានពោរពេញទៅដោយអំពើបាប។ គ្រីស្ទបរិស័ទបច្ចុប្បន្នត្រូវការអនុវត្តន៍សេចក្តីទាំងពីរយ៉ាងនេះ មួយគឺអនុវត្តគោលជំនឿរបស់ខ្លួនដែលជាទ្រឹស្តី ទាក់ទងនឹងសិទ្ធិសេរីភាពទទួលបានជាកូនរបស់ព្រះជាម្ចាស់។ មិនតែប៉ុណ្ណោះគ្រីស្ទបរិស័ទត្រូវការគោលទ្ធិនៃការដើរក្នុងជីវិតបរិសុទ្ធ និងការរស់នៅប្រចាំថ្ងៃក្នុងជីវិតរបស់យើង។ នៅក្នុងវគ្គគោលទ្ធិសាវ័កប៉ុលចែកជាបីផ្នែកទៅទៀតគឺ ជំពូក១ លោកបរិយាយពីក្រុមជំនុំរបស់ព្រះជាម្ចាស់ជារូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ជំពូកពីរ លោកបរិយាយថា ក្រុមជំនុំជា

វិហាររបស់ទ្រង់។ ឯជំពូកបីវិញ លោកបរិយាយថា ក្រុមជំនុំរបស់ព្រះគឺជាអាថ៌កំបាំង។

ចំណែកវគ្គទីពីរ គឺជំពូក៤-៦ លោកបរិយាយថា ជំពូក៤ ជាការអនុវត្តន៍របស់អ្នកជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ជំពូក៤ គឺជាមនុស្សថ្មី។ ក្រុមជំនុំរបស់ព្រះជាម្ចាស់ ជាសង្គមរបស់មនុស្សថ្មី ត្រូវដើរក្នុងលោកនេះដោយកម្លាំងថ្មីរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ជំពូក៥បរិយាយថា ក្រុមជំនុំរបស់ព្រះជាម្ចាស់នឹងផ្លាស់ប្រែទៅជាភរិយាថ្មោងថ្មីរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សូមលោកអ្នកកុំអោយយល់ច្រឡំថា ក្រុមជំនុំរបស់ព្រះជាម្ចាស់សព្វថ្ងៃនេះ ជាភរិយាថ្មោងថ្មីរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទអោយសោះ។ សាវ័កប៉ុលបញ្ជាក់ពីដំណើរនេះក្នុងគម្ពីរ២កូរិនថូស១១:២ថា "ពីព្រោះខ្ញុំប្រចណូចំពោះអ្នករាល់គ្នា ដោយសេចក្តីប្រចណូនៃព្រះ ដ្បិតខ្ញុំបានបំរុងអ្នករាល់គ្នាទុក ឱ្យមានប្តីតែ១ ទុកដូចជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅព្រះគ្រីស្ទតែមួយប៉ុណ្ណោះ"។ ត្រង់នេះសាវ័កប៉ុលចង់មានប្រសាសន៍ថា ក្នុងពេលបច្ចុប្បន្ននេះ ក្រុមជំនុំគ្រាន់តែជាគូដណ្តឹងរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតែប៉ុណ្ណោះទេ។ ក្នុងគ្រាអនាគត ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នឹងក្លាយទៅជាភរិយាថ្មោងថ្មីរបស់ព្រះអង្គ។ ចំណែកក្នុងជំពូក៦វិញ សាវ័កប៉ុលសម្តែងថា ក្រុមជំនុំរបស់ព្រះជាម្ចាស់ប្រៀបឧបមាដូចជាពលទាហាន។ ដោយសារជំពូក៤បរិយាយពីក្រុមជំនុំជាភរិយារបស់ព្រះគ្រីស្ទ ឯជំពូក៦និយាយអំពីក្រុមជំនុំជាទាហាន មិនមែនមានន័យថា បន្ទាប់ពីរៀបការហើយ ក្រុមជំនុំនិងព្រះគ្រីស្ទអាចទាស់ទែងគ្នាទេ។ ក្នុងចំណុចនេះ សាវ័កប៉ុលចង់សម្តែងថា ក្នុងនាមយើងជាក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងមានសត្រូវខាងវិញ្ញាណ

ច្រើនណាស់។ សាតាំងដែលជាមេគ្រប់គ្រងលើវិញ្ញាណអួសទាញនាំពួកជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទអោយរស់នៅខ្វះប្រសិទ្ធភាព តែងតែធ្វើទុក្ខបុកម្នេញដល់ពួកអ្នកជឿជារៀងរាល់ថ្ងៃ។ ក្នុងនាមយើងជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងត្រូវរស់នៅលើលោកនេះ ដោយប្រយ័ត្នខ្លួនដឹងជានិច្ចថា សាតាំងជាមេល្បួង មិនបណ្តោយអោយក្រុមជំនុំរបស់ព្រះជាម្ចាស់រស់នៅដោយសុខសាន្តឡើយ។ ក្រុមជំនុំចាំបាច់ត្រូវពាក់អស់ទាំងគ្រឿងសឹករបស់ព្រះ ដើម្បីតទល់ជាមួយនឹងពួកសាតាំង។ ការរស់នៅលើលោកនេះងាយនឹងប្រព្រឹត្តអំពើបាប។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ យើងត្រូវការកម្លាំងរបស់ព្រះជាម្ចាស់ ដើម្បីឈរក្នុងជំហរមួយបង្ហាញថា យើងមានព្រះជាម្ចាស់គង់នៅជាមួយយើង ពេលដែលយើងរស់នៅជាក្រុមជំនុំរបស់ព្រះអង្គនៅលើផែនដីនេះ។

យើងស្វែងការសិក្សាគម្ពីរអេភេសូរត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ជើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"